# សរុបព្រឹត្តការណ៍ប្រចាំថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០
## សម្រាប់ វីរុស COVID-19

### ១. កោះសន្តិភាព ៖ covid-19មិនមែនជាជំនឿបែបអរូបី

កោះសន្តិភាព KOH SANTEPHEAP MEDIA




ទំព័រមុខ ▸ សិល្បៈនិងវប្បធម៌ ▸ ជ្រុងមួយនៃសាសនា ▸ covid-19មិនមែនជាជំនឿបែបអរូបី

## covid-19មិនមែនជាជំនឿបែបអរូបី

ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១៧:២៤ សាន សារិន Share Like 3.8K

អត្រាប្តូរប្រាក់

| ប្រាក់រៀល (1USD) | KHR 1USD : 4087 |
| --- | --- |

អត្រាប្តូរប្រាក់ផ្សេងទៀត






វីរុសកូរ៉ូណា ឬហៅបែបម្យ៉ាងទៀតថា វីរុស covid-19 មិនមែនជាជំនឿបែបអរូបីឡើយ វាជាមេរោគឆ្លងយ៉ាងសាហាវបំផុតធ្វើឱ្យពិភពលោកនេះរន្ធត់ញាប់ញ័រភ័យខ្លាចឥទ្ធិពលរបស់វាក្រៃលែង ឯវិធីការពារការចម្លងមេរោគនេះដ៏មានប្រសិទ្ធភាពគឺត្រូវពាក់ម៉ាស ត្រូវមានអនាម័យ ពិសេសត្រូវទទួលទានទឹកឱ្យច្រើន មិនអាចយកពិធីបន់ស្រន់ ឬសូត្របណ្ដេញមេរោគនេះបានឡើយ តែក៏មិនខុសឆ្គងទៅនឹងជំនឿរបស់អ្នកស្រុក ឬខុសឆ្គងទៅនឹងធម៌វិន័យអ្វីឡើយ ធ្វើក៏ធ្វើចុះតែគួរប្រកបដោយបញ្ញា ។






មានអ្នកស្រុកច្រើនណាស់ ក្នុងនោះមានទាំងព្រះសង្ឃផងដែរ ដែលមានជំនឿថា ការបន់ស្រន់ ការបួងសួង ការសូត្រធម៌បណ្ដេញ ឬម្រាប់គ្រោះភ័យចង្រៃទាំងឡាយ នឹងធ្វើឱ្យមេរោគដ៏សាហាវនេះរលត់ រលាយ បរវាសចៀសចេញឆ្ងាយ អន្តរាយខ្ចាត់ខ្ចាយអស់គ្មានសល់ ដោយអំណាចនៃការបួងសួង ការសូត្រធម៌បណ្ដេញនឹងធ្វើឱ្យមេរោគទាំងនោះមិនហ៊ានមកក្បែរឡើយ ។

ទស្សនៈទាំងនេះអាចផ្ទុយទៅនឹងទស្សនៈអង្គការសុខភាពពិភពលោកដែលយល់ថា វិធីការវីរុសកូវីដ-19បានមានតែពាក់ម៉ាសក្នុងទីប្រជុំជន រស់នៅដោយមានអនាម័យលាងដៃនឹងសាប៊ូជាញឹកៗ ពិសេសត្រូវទទួលទានទឹកឱ្យបានច្រើនដើម្បីលាងសម្អាតមេរោគក្នុងខ្លួន គឺធ្វើយ៉ាងណាកុំឱ្យស្ងួតបំពង់កដែលប្រឈមនឹងការលូនចូលនៃមេរោគនេះ ។ សាន សារិន

## ២. កោះសន្តិភាព៖ ថៃលីគប្រកាសផ្អាកការប្រកួតទាំងអស់ ការពារឆ្លងវីរុស Covid-19

កោះសន្តិភាព KOH SANTEPHEAP MEDIA




ទំព័រមុខ ▸ ព័ត៌មានកីឡា ▸ កីឡាអន្តរជាតិ ▸ ថៃលីគប្រកាសផ្អាកការប្រកួតទាំងអស់ ការពារឆ្លងវីរុស Covid-19

# ថៃលីគប្រកាសផ្អាកការប្រកួតទាំងអស់ ការពារឆ្លងវីរុស Covid-19

ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១៣:៤៣ វិរៈបុត្រ

Share Like 234



យោងតាមការប្រកាសពី Thai League បានឱ្យដឹងថា ការប្រកួតបាល់ទាត់លីគថៃទាំងអស់ចាប់តាំងពីលីគទី ១-៤ នឹងត្រូវផ្អាកចាប់ពីថ្ងៃទី៣ មីនា ដល់ថ្ងៃទី១៧ មេសា ២០២០ ស្របតាមគោលនយោបាយរបស់ក្រសួងសុខាភិបាលថៃ ក្នុងការខិតខំទប់ស្កាត់ការរីករាលដាលនៃជំងឺរលាកផ្លូវដង្ហើម ដែលបណ្តាលមកពីវីរុស COVID-19 ។

ងាកមកកាន់ការប្រកួតលីគកំពូលថៃ បច្ចុប្បន្នក្រុម Bangkok United កំពុងតែឈរនៅកំពូលតារាងបណ្តោះអាសន្ន ក្រោយឆ្លងកាត់ ៤ប្រកួតឈ្នះទាំង៤ មាន១២ពិន្ទុស្មើពិន្ទុគ្នាជាមួយក្រុមលេខ២ Ratchaburi។

សូមបញ្ជាក់ថា បើយោងតាមប្រភពពី CNN បានឱ្យដឹងថា គិតមកទល់ពេលនេះ ក្នុងប្រទេសថៃបានរកឃើញករណីឆ្លងចំនួន ៤២ករណី និងបានឆក់យកជីវិតមនុស្សម្នាក់ផងដែរ ដោយសារវីរុសនេះ ។ (កែសម្រួលដោយ ៖ ធីតា)

អត្រាប្តូរប្រាក់

| ប្រាក់រៀល (1USD) | KHR 1USD : 4087 |
|---|---|

អត្រាប្តូរប្រាក់ផ្សេងទៀត >




## ៣. កោះសន្តិភាព៖ ប្រជាពលរដ្ឋក្រុងបាងកកសម្រុកទិញស្បៀងអាហារទុក ព្រោះខ្លាចជំងឺកូរ៉ូណាថ្មី

កោះសន្តិភាព KOH SANTEPHEAP MEDIA




ទំព័រមុខ ▸ ព័ត៌មានអន្តរជាតិ ▸ ព្រឹត្តិការណ៍អន្តរជាតិ ▸ ប្រជាពលរដ្ឋក្រុងបាងកកសម្រុកទិញស្បៀងអាហារទុក ព្រោះខ្លាចជំងឺកូរ៉ូណាថ្មី

# ប្រជាពលរដ្ឋក្រុងបាងកកសម្រុកទិញស្បៀងអាហារទុក ព្រោះខ្លាចជំងឺកូរ៉ូណាថ្មី

ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១១:៤៥ គង់ រិទ្ធីណា

Share

អត្រាប្តូរប្រាក់

| ប្រាក់រៀល (1USD) | KHR 1USD : 4087 |
|---|---|

អត្រាប្តូរប្រាក់ផ្សេងទៀត >

ក្រុងបាងកក ៖ អ្នកទិញអីវ៉ាន់នៅក្រុងបាងកកកំពុងនាំគ្នាសម្រុកទិញស្បៀងអាហារដែលអាចទុកបានយូរអស់ពីក្នុងផ្សារទំនើប ដែលទាំងនោះមានដូចជា មី អង្ករ ក្រដាស់ជូតមាត់ ត្រីខកំប៉ុង និង ទឹកសុទ្ធ ដោយសារតែភាពភ័យខ្លាចនឹងជម្ងឺក្លូរ៉ូណាថ្មី COVID-19។

ហាងលក់ធំៗ រួមមាន Tops Supermarket, Tesco Lotus, The Mall Group និង Big C Super center បានទទួលស្គាល់ថា របស់ទាំងនេះត្រូវបានគេទិញយ៉ាងលឿន ចាប់តាំងពីចុងសប្តាហ៍មុនមក។ ពួកគេក៏មានការឯកភាពផងដែរថា ការភ័យខ្លាចនៃវីរុសដែលបង្កគ្រោះថ្នាក់គឺជាបុព្វហេតុចម្បងសម្រាប់ការទិញទំនិញ។

លោក Chairat Petchdakul អនុប្រធានផ្នែកលក់ទំនិញនៅក្រុមហ៊ុន The Mall Group Co ដែលបង្កើតផ្សារទំនើប Gourmet Market បានមានប្រសាសន៍ថា «យើងមិនដែលឃើញការទិញសម្រុកបែបនេះទេ»។

លោកមានប្រសាសន៍ថា ដំបូងយើងគិតថា នេះគឺដោយសារតែគេទើបតែនឹងបើកប្រាក់ខែ តែក្រោយមកក៏សង្កេតឃើញថា ទំនិញដែលគេទិញភាគច្រើនគឺជាគ្រឿងទុកប្រើប្រាស់រយៈពេលយូរ។ នេះគឺអាចមានហេតុផលគ្រប់គ្រាន់ថា វាគឺដោយសារតែការភ័យខ្លាចនឹងការឆ្លងជម្ងឺក្លូរ៉ូណាថ្មី។

លោកបានផ្តល់ការធានាថា ការផ្គត់ផ្គង់ផលិតផលដែលបានលើកឡើងខាងលើ គឺគ្រប់គ្រាន់ទោះបីជាមានការយឺតយ៉ាវបន្តិចក្នុងការចែកចាយពីអ្នកផលិតក៏ដោយ។ ក្រុមហ៊ុន The Mall Group និយាយថា ខ្លួនបានបង្កើនចំនួនទំនិញបែបនេះទ្វេដងពីការផ្គត់ផ្គង់រយៈពេល ១៥ថ្ងៃទៅ ៣០ថ្ងៃ ដើម្បីការពារកង្វះខាតនិងធានាថាអតិថិជនមានការផ្គត់ផ្គង់ផលិតផលគ្រប់គ្រាន់ដែលពួកគេកំពុងស្វែងរក៕ យោងតាមប្រភពពីផ្សាយ Bangkokpost (កែសម្រួលដោយ ៖ ធីតា)

## ៤. កោះសន្តិភាព៖ កម្ពុជាប្រឈមបាត់បង់ចំណូលជិត ១លានដុល្លារពីវិស័យទេសចរណ៍ដោយសារ Covid-19

កោះសន្តិភាព KOH SANTEPHEAP MEDIA




ទំព័រមុខ ▸ ព័ត៌មានជាតិ ▸ ព័ត៌មានសេដ្ឋកិច្ច ▸ កម្ពុជាប្រឈមបាត់បង់ចំណូលជិត ១លានដុល្លារពីវិស័យទេសចរណ៍ដោយសារ Covid-19

# កម្ពុជាប្រឈមបាត់បង់ចំណូលជិត ១លានដុល្លារពីវិស័យទេសចរណ៍ដោយសារ Covid-19

អត្រាប្តូរប្រាក់

| ប្រាក់រៀល (1USD) | KHR 1USD : 4087 |
|---|---|

អត្រាប្តូរប្រាក់ផ្សេងទៀត >

ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ០៧:៤០ ឡុង សាផេត

Share Like 247

រាជធានីភ្នំពេញ៖ មន្ត្រីកំពូលនៃក្រសួងទេសចរណ៍បង្ហាញការព្យាករណ៍របស់ខ្លួនថា នៅឆ្នាំ ២០២០នេះកម្ពុជាប្រឈមការបាត់បង់ប្រាក់ចំណូលពីវិស័យទេសចរណ៍មានរហូតដល់ជិត១លានដុល្លារអាមេរិកដែលបង្កដោយ វីរុសក្លូរ៉ូណា-១៩ (Covid-19) ដោយផ្អែកលើទិន្នន័យ ដែលកម្ពុជាទទួលបានភ្ញៀវទេសចរបរទេសប្រមាណ ៦,៦លាននាក់កាលពីឆ្នាំ ២០១៩ ។

លោក ទិត ចន្ថា រដ្ឋលេខាធិការប្រចាំការនៃក្រសួងទេសចរណ៍មានប្រសាសន៍ក្នុងសន្និ សីទសារព័ត៌មានស្តីពី « វឌ្ឍនៈភាព និងទិសដៅការងារបន្តរបស់ក្រសួងទេសចរណ៍កាល ពីថ្ងៃទី ២ខែមីនា ឆ្នាំ ២០២០នេះថា ទាក់ទងនិងចំណូលនៅក្នុងវិស័យទេចរណ៍កាលពីឆ្នាំ ២០១៩ ទទួលបានពីទេសចរអន្តរជាតិមានប្រមាណជាង ៥.០០០លានដុល្លារអាមេរិក ហើយទេសចរក្នុងស្រុកមានប្រមាណ ៥០០លានដុល្លារអាមេរិកដែលបានចាក់បញ្ចូលទៅ ក្នុងចរន្តសេដ្ឋកិច្ចជាតិ ។

លោករដ្ឋលេខាធិការបន្តថា «តាមការសិក្សាអំពីផលប៉ះពាល់ដែលបង្កដោយ Covid-19 យើងបាននិងកំពុងសិក្សារឿងនេះយ៉ាងលម្អិត ពិសេសធ្វើការជាមួយផ្នែកក្រសួងពាក់ព័ន្ធ ។ យើងមានការថមថយនៃភ្ញៀវទេសចរនៅទូទាំងប្រទេសនៅពីរខែដើមឆ្នាំ ២០២០នេះ មានប្រមាណ ១៥% ។ តែបើសិនសេនារីយោដែលបានបញ្ជាក់ថានៅដើមឆ្នាំ ២០២០នេះ មានស្ថានភាពប្រសើឡើងខ្លះមកវិញ អីចឹងសរុបនៅឆ្នាំ ២០២០មានក្នុងរង្វង់ ១០% ផលប៉ះពាល់នេះធ្វើឱ្យបាត់ចំណូលដែលយើងធ្លាប់ទទួលបានដូចឆ្នាំ ២០១៩ ពីភ្ញៀវ ទេសចរអន្តរជាតិ» ។

លោក ទិត ចន្ថា មានប្រសាសន៍ទៀតថា « កាលពីជំងឺសារនៅឆ្នាំ ២០០២ ឬ ២០០៣ យើង ក៏ថយ ១០% តែកាលនោះទេសចរអន្តរជាតិដែលកម្ពុជាទទួលបានក្នុងឆ្នាំ ២០០៣ មាន ប្រមាណ ៧០ម៉ឺននាក់ តែមកដល់ឆ្នាំ ២០១៩ នេះមាន ៦,៦លាននាក់ ។ កម្ពុជាទទួលបាន ភ្ញៀវទេសចរអន្តរជាតិ ៧០ម៉ឺននាក់យើងថយ ១០% យើងបាត់ចំណូល ៧ម៉ឺនដុល្លារអា មេរិក ប៉ុន្តែឥឡូវនេះយើងមាន ៦,៦លាននាក់ថយចុះ ១០% មានប្រហែល ៦៦ម៉ឺនដុល្លារ ឬប្រហាក់ប្រហែល ១លានដុល្លារអាមេរិកនៃការថមថយចំណូលដែលមកពីវិស័យ ទេសចរណ៍» ។

ទន្ទឹមនឹងការព្យាករណ៍ថាកម្ពុជាប្រឈមការបាត់ចំណូលជិត ១លានដុល្លារអាមេរិកនៅឆ្នាំ ២០២០នេះ បើតាមថ្នាក់ដឹកនាំក្រសួងទេសចរណ៍ គឺក្រសួងបានដាក់ចេញ ឬមានវិធានា ការធំៗចំនួន ៤ ដើម្បីឆ្លើយតបនឹងដោះស្រាយចំពោះមុខដែលបង្កដោយ វីរុស Covid 19 នេះ ។
រដ្ឋលេខាធិការប្រចាំការនៃក្រសួងទេសចរណ៍លើកឡើងថា យើងមានវិធានការសំខាន់ធំៗ ៤ ក្នុងការដាក់ចេញ ឆ្លើយតបនឹងជំរុញការដោះស្រាយបញ្ហានៃការអភិវឌ្ឍវិស័យទេសចរ ណ៍ ទប់ទល់កត្តាអវិជ្ជមានពីកត្តាខាងក្រៅ Covid 19 ហើយនៅក្នុងវិធានាការគោលធំៗ ដែលរៀបចំដោយក្រសួងទេសចរណ៍កម្ពុជា ក៏ដូចជាការទទួលអនុវត្តតាមការណែនាំពី ថ្នាក់ដឹកនាំ ។ យើងបានពង្រីកវិធានការទាំងនោះទៅជាការអភិវឌ្ឍន៍ នៃសកម្មភាពនៅ ក្នុងដំណាក់កាលដោះស្រាបបញ្ហា ឬឆ្លើយតប ។

លោកបន្តថា អំពីវិធានការចំពោះមុខដែលជាវិធានការអាទិភាពទាំង ៤ ដែលក្រសួងទេស ចរណ៍បានដាក់ចេញ និងអនុវត្តប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ នឹងជំរុញឱ្យមាន ប្រសិទ្ធភាពក្នុងការឆ្លើយតបបានទាន់ពេលវេលាពីបញ្ហា Covid 19 រួមមាន៖ ទី ១- ជំរុញសកម្មភាពសទេសចរណ៍ផ្ទៃក្នុង នៅពេលមានការថមថយនៃស្ថានភាពទេសចរណ៍អន្តរជាតិមកដល់ដែលយើងបានដឹងហើយថាវាជាបញ្ហាសកល ។ នៅពីរខែ ដើមឆ្នាំ ២០២០នេះមានការថមថយក្នុងរង្វង់ ១៥% នៃទេសចរអន្តរជាតិធ្លាប់តែមាន កំណើន ។ ទី ២-នៅតែស្វាគមន៍លំហូរទេសចរអន្តរជាតិដោយមិនមានការរឹតបណ្តឹង ឬបិទអ្វីទាំងអស់ គឺមានតែការជួយសម្រួលធ្វើយ៉ាងណាឱ្យការធ្វើដំណើរមានភាពងាយស្រួលដើម្បីទាក់ទាញទេសចរអន្តរជាតិចូលកម្ពុជា ។

ប៉ុន្តែស្របគ្នានេះយើងបានដាក់ចេញ វិធានការបង្ការ ទប់ស្កាត់ និងដោះស្រាយ ។ ទី ៣- ធ្វើឱ្យគោលដៅទេសចរណ៍សំខាន់ៗ គឺអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឱកាសដែលភ្ញៀវមានការថមថយខ្លះ គឺយើងយក ពេលក្នុងការរៀបចំផ្ទះសំបែង ផលិតផល ហេដ្ឋារចនាសម្ព័ន្ធឱ្យស្អាត ដើម្បីត្រៀមនៅពេល បញ្ហានេះត្រូវបានដោះស្រាយ យើងសង្ឃឹមថានឹងមានភ្ញៀវទេសចរមកកាន់កម្ពុជាច្រើន និង ទី ៤- បើសិនយើងឃើញមានការប៉ះពាល់ គឺរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ ជួយសម្រួលការលំបាកពិសេសជួយទៅដល់អ្នកប្រកបរបរក្នុងវិស័យទេសចរណ៍ ។

បើតាមមន្ត្រីជាន់ខ្ពស់ក្រសួងទេសចរណ៍កាលពីឆ្នាំ ២០១៩ កន្លងទៅនេះកម្ពុជាទទួលបាន ភ្ញៀវទេសចរអន្តរជាតិប្រមាណ ៦,៦លាននាក់ហើយមានកំណើនបន្ថែមប្រមាណ ៦,៦% ។ នៅក្នុងអត្រានេះឃើញថាវិស័យទេចរណ៍បានចូលរួមវិភាគទានយ៉ាងខ្លាំងដល់ការជំរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជាតាមរយៈកំណើនវិស័យទេសចរណ៍ការអភិវឌ្ឍសង្គមកម្ពុជា ក្នុងនោះវិស័យទេសចរណ៍បានរួមចំណែកប្រមាណជាង ១៣% នៃផលិតផលសរុបក្នុងស្រុក (ផ.ស.ស ) របស់កម្ពុជា ហើយថែមទាំងបានបង្កើតការងារ ៦៣ម៉ឺនកន្លែងដោយ ផ្ទាល់ និងរាប់ម៉ឺនកន្លែងផ្សេងទៀតដោយប្រយោលនៅកម្ពុជា ។ កែសម្រួលដោយ ៖ សុឃាក់

## ៥. កម្ពុជាថ្មី៖ រាជរដ្ឋាភិបាលថា អាទិភាពចម្បងរបស់កម្ពុជាពេលនេះ គឺរួមគ្នាប្រយុទ្ធប្រឆាំងជំងឺឆ្លងកូវីដ-១៩ (កូរ៉ូណា)

ទំព័រដើម | ព័ត៌មាន | KPT PLUS | កម្សាន្ត | កីឡា | សុខភាព | បច្ចេកវិទ្យា | ហោរាសាស្ត្រ | ការ



# រាជរដ្ឋាភិបាលថា អាទិភាពចម្បងរបស់កម្ពុជាពេលនេះ គឺរួមគ្នាប្រយុទ្ធប្រឆាំងជំងឺឆ្លងកូវីដ-១៩ (កូរ៉ូណា)

4/3/2020 5:07 Pm ព័ត៌មានជាតិ, ព័ត៌មានថ្មីៗ, សុខភាព 1

នៅមុននេះបន្តិចក្នុងពេលថ្លែងសុន្ទរកថាបិទសន្និបាតសុខាភិបាលលើកទី៤១ នៅសណ្ឋាគារសុខា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជាបានប្រកាសជាសាធារណៈថា ការងារអាទិភាពសំខាន់ចម្បងបំផុតរបស់កម្ពុជានាពេលនេះ គឺប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ (កូរ៉ូណា)។

ការយុទ្ធប្រឆាំងមានប្រសិទ្ធិភាពទៅបានលុះត្រាតែមានការចូលរួមពីគ្រប់គ្នាចាប់ពីមនុស្សម្នាក់ រហូតដល់ប្រជាពលរដ្ឋ ទូទាំងប្រទេសប្រទេស។ នេះបើតាមប្រសាសន៍របស់សម្តេច។ ពលរដ្ឋទាំងអស់ក៏ត្រូវធ្វើអនាម័យលាងដៃជាប្រចាំផងដែរ៕

## ៦. កម្ពុជាថ្មី៖ រហូតដល់ម៉ោង ១១:៣៤នាទីថ្ងៃត្រង់ ថ្ងៃទី ៤ មីនា ២០២០ ពុំទាន់រកឃើញករណីជំងឺកូរ៉ូណាវីរុសប្រភេទថ្មីបន្ថែមទៀតទេ

ទំព័រដើម | ព័ត៌មាន | KPT PLUS | កម្សាន្ត | កីឡា | សុខភាព | បច្ចេកវិទ្យា | ហោរាសាស្ត្រ | ការងារ និង

# រហូតដល់ម៉ោង ១១:៣៤នាទីថ្ងៃត្រង់ ថ្ងៃទី ៤ មីនា ២០២០ ពុំទាន់រកឃើញករណីជំងឺកូរ៉ូណាវីរុសប្រភេទថ្មីបន្ថែមទៀតទេ

4/3/2020 1:36 Pm ព័ត៌មានជាតិ, ព័ត៌មានថ្មីៗ, សុខភាព

♡ 1

រហូតដល់ម៉ោង ១១:៣៤នាទីថ្ងៃត្រង់ ថ្ងៃទី ៤ មីនា ២០២០ ពុំទាន់រកឃើញករណីជំងឺកូរ៉ូណាវីរុសប្រភេទថ្មីបន្ថែមទៀតទេ។ នេះបើតាមទំព័រហ្វេសបុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។

ក្រសួងសុខាភិបាលបានធ្វើតេស្តសរុបកើនដល់២៧៤ នាក់ នៅវិទ្យាស្ថានប៉ាស្ទ័រ តែមិនមានរកឃើញមេរោគCOVID-19 ទេ ។ អ្នកទេសចរណ៍ ៩១ ជាតិសាសន៍ លើនាវាយក្ស Westerdam ជាង២០០០នាក់ ដែលត្រលប់ទៅមាតុប្រទេសរៀងៗវិញ មិនបានរកឃើញផ្ទុកមេរោគកូរ៉ូណាវីរុសប្រភេទថ្មីទេពីប្រទេសទាំងនោះ ។ ក្រុមឆ្លើយតបបន្ទាន់ និងក្រុមគ្រូពេទ្យដែលបានបណ្តុះបណ្តាលអំពីឆ្លើយតបទៅនឹងជំងឺរាតត្បាតជាង២០០០នាក់កំពុងបន្តតាមដានរុករកករណី ។ ក្រុមគ្រូពេទ្យតាមព្រំដែន (មន្ត្រីចត្តាឡីស័ក) បានកំពុងឃ្លាំមើលអ្នកដំណើរចេញចូលគ្រប់ច្រកតាមព្រំដែន គោគ ថៃ ឡាវ វៀតណាម ផ្លូវសមុទ្រ និងអាកាសយានដ្ឋានអន្តរជាតិទាំង៣ ភ្នំពេញ សៀមរាប ក្រុងព្រះសីហនុ តាមរយៈម៉ាស៊ីនស្ទង់កំដៅនិងពិនិត្យសុខភាព ។

មន្ទីរពិសោធន៍វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដំណើរការទាំងថ្ងៃទាំងយប់ធ្វើតេស្តវត្ថុវិភាគ ដែលបានផ្ញើវត្ថុវិភាគមកពីទូទាំងប្រទេស និងយើងត្រៀមមន្ទីរពិសោធន៍ពីរទៀតក្នុងក្រសួងសុខាភិបាលដើម្បីជំនួយកក្នុងការធ្វើតេស្តបន្ថែមទៀត ។ ក្រសួងមានមន្ត្រីជំនាញ ១០រូប កាន់ទូរស័ព្ទដៃដើម្បីទទួលទូរស័ព្ទបាញ់ពីលេខ ១១៥ ដើម្បីទទួលរាយការណ៍ករណីសង្ស័យពីប្រជាពលរដ្ឋពីទូទាំងប្រទេស ។

ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥
ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ជាប្រព័ន្ធទូរស័ព្ទបានអភិវឌ្ឍន៍ទៅជាបច្ចេកវិទ្យាទំនើប និងសំរាប់ផ្តល់សេវាជូនប្រជាពលរដ្ឋទូទាំងប្រទេសនូវ ៖

១. ចំណេះដឹងទាក់ទងនឹងជំងឺកូរ៉ូណាវីរុសប្រភេទថ្មី និងជំងឺឆ្លងផ្សេងៗទៀត
២. អាចរាយការណ៍ករណីជំងឺសង្ស័យ និងកើតឡើងច្រើនខុសធម្មតាក្នុងទីតាំងណាមួយ
៣. អាចសួរព័ត៌មានឬចំណេះដឹងបន្ថែមទាក់ទងនឹងជំងឺកូរ៉ូណាវីរុសប្រភេទថ្មី និងជំងឺឆ្លងផ្សេងៗទៀត
៤. យើងមានសហការីជំនាញសុខាភិបាល ១០រូបចាំទទួលទូរស័ព្ទ ដោយប្រើបច្ចេកវិទ្យាប្រព័ន្ធបញ្ជូនទៅទូរស័ព្ទដៃទៅគ្រូពេទ្យទាំង១០នាក់ (Calling Forward System)។

## ៧. កម្ពុជាថ្មី៖កាកបាទក្រហមកម្ពុជាសម្រេចផ្អាកការប្រារព្ធទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទ ក្រហម៨ ឧសភា ២០២០ទ្រង់ទ្រាយធំ





# កាកបាទក្រហមកម្ពុជាសម្រេចផ្អាកការប្រារព្ធទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទ ក្រហម៨ ឧសភា ២០២០ទ្រង់ទ្រាយធំ

4/3/2020 9:22 Pm ជាតិទូទៅ, ព័ត៌មានជាតិ

like

ភ្នំពេញ ៖ កាកបាទក្រហមកម្ពុជា បានសម្រេចផ្អាកការប្រារព្ធមិទ្ទីងថ្នាក់ជាតិ ដើម្បីអបអរខួបលើកទី ១៥៧ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទ ក្រហម ៨ ឧសភា ២០២០ដែលគ្រោងនឹងរៀបចំឡើងនៅថ្ងៃ ៨ ឧសភា ២០២០ នៅ ទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជាក្នុងបរិការណ៍ដែលពិភពលោកក៏ដូចជាព្រះរាជាណាចក្រកម្ពុជា កំពុងខិតខំប្រឹងប្រែងគ្រប់គ្រងផលប៉ះពាល់ពីជំងឺរលាកផ្លូវ ដង្ហើម ធ្ងន់ធ្ងរ កូវីដ-១៩ (COVID-19) មកលើសង្គម និងសេដ្ឋកិច្ចជាតិ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់កាកបាទក្រហមកម្ពុជា ដែលបានចេញផ្សាយកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ បានឲ្យដឹងថា ទោះបីជាមិនមានការរៀបចំពីធីអបអរខួបលើកទី ១៥៧ ទិវាពិភពលោក កាកបាទ ក្រហម អឌ្ឍចន្ទក្រហម ដូចធ្លាប់បានធ្វើជារៀងរាល់ឆ្នាំក្តីក៏កាកបាទក្រហមកម្ពុជា នៅតែបន្ត កៀរគរមូលនិធិ និងស្វាគមន៍ការចូលរួមជាវិភាគទានពីសំណាក់ សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាសប្បុរសជន ទាំងក្នុងវិស័យរដ្ឋ និងវិស័យឯកជន ដូចធ្លាប់បានធ្វើកាលពីឆ្នាំកន្លងទៅ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

មូលនិធិដែលកាកបាទក្រហមកម្ពុជា ទទួលបានពីសប្បុរសជនគ្រប់មជ្ឈដ្ឋានទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិអាចជួយធ្វើឲ្យកាកបាទក្រហមកម្ពុជាមានធនធានអាចធ្វើប្រតិបត្តិការសប្បុរសធម៌របស់ខ្លួន ដោយពុំមានការរើសអើងសំដៅក្នុងការចូលរួមជួយសង្គ្រោះជីវិត ការកសាងនូវភាពធនទៅនឹងគ្រោះមហន្តរាយផ្សេងៗ កាត់បន្ថយអត្រាឈឺនិងស្លាប់របស់ម្តាយនិងកុមារ ការលើកកម្ពស់គោលការណ៍គ្រឹះនៃតម្លៃមនុស្សធម៌ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិនិងវប្បធម៌អហិង្សា។ល។

កាកបាទក្រហមកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជនមកពីគ្រប់មជ្ឈដ្ឋាន ទាំងក្នុងវិស័យរដ្ឋ និងវិស័យឯកជននិងមេត្តាបន្តចូលរួមជាកម្លាំងមនុស្សធម៌ ជាមួយ កាកបាទ ក្រហមកម្ពុជា ដើម្បីជួយសម្រាលទុក្ខលំបាករបស់បង-ប្អូនប្រជាពលរដ្ឋ ដែលងាយរងគ្រោះ បំផុតរួមមាន ៖ អ្នករងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ជនពិការ ចាស់ជរាឥតទីពឹង កុមារកំព្រា ស្ត្រីមេម៉ាយ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍៕

## ៨. កម្ពុជាថ្មី៖សម្តេចតេជោ ហ៊ុន សែន បានស្នើសុំក្រសួងស្ថាប័នរដ្ឋ ចូលរួមសន្សំសំចៃថវិកាជាតិក្នុងពេលប្រទេសជាតិដាក់ចេញនូវវិធានការទប់ស្កាត់ជំងឺឆ្លងកូវីដ-១៩



# សម្តេចតេជោ ហ៊ុន សែន បានស្នើសុំក្រសួងស្ថាប័នរដ្ឋ ចូលរួមសន្សំសំចៃថវិកាជាតិក្នុងពេលប្រទេសជាតិដាក់ចេញនូវវិធានការទប់ស្កាត់ជំងឺឆ្លងកូវីដ-១៩

4/3/2020 8:58 Pm ជាតិទូទៅ, ព័ត៌មានជាតិ

like

នៅក្នុងឱកាសអញ្ជើញបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ នៃក្រសួងសុខាភិបាល នៅសណ្ឋាគារសុខា ថ្ងៃទី ៤ ខែ មីនា ស្របពេលដែល សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានសម្រេចដាក់ចេញនូវអាទិភាពចម្បងរបស់ប្រទេសកម្ពុជានាពេលនេះ គឺរួមគ្នាប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ (កូរ៉ូណា) គឺ សម្តេចតេជោ ហ៊ុន សែន បានសម្រេចឲ្យក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជាទាំងអស់ត្រូវកាត់បន្ថយការចំណាយរបស់ខ្លួន ៥០% ។ ប៉ុន្តែលើកលែងតែក្រសួងនិងស្ថាប័នបីដូចជា ១)ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ២)ក្រសួងពាណិជ្ជកម្ម ៣)ទីស្តីការគណៈរដ្ឋមន្ត្រី គឺត្រូវកាត់បន្ថយការចំណាយរបស់ខ្លួន ២៥% ។

ចំពោះការចំណាយ និងបញ្ជូនមន្ត្រីទៅបេសកកម្មក្រៅប្រទេស ឧទាហរណ៍បើទៅ ៥នាក់ គឺឲ្យទៅតែ២នាក់ទេ ។ ទន្ទឹមនឹងនោះ គឺត្រូវផ្តល់ការងារឲ្យអគ្គរាជទូតប្រចាំការនៅក្រៅប្រទេសចូលរួមប្រជុំជំនួស។

ការកាត់បន្ថយចំណាយចរន្តនេះ គឺរាជរដ្ឋាភិបាលកម្ពុជាអាចសន្សំថវិកាបានប្រមាណ ៥០០លានដុល្លារអាមេរិក ដែលអាចយកមកដោះស្រាយបញ្ហាប្រឈមចាំបាច់នានា។ សម្តេចតេជោបានបញ្ជាក់ច្បាស់ថា មិនមានការកាត់បន្ថយលើការតម្លើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឡើយនៅក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ និងភ្ជុំបិណ្ឌ។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នឹងបន្តតាមដានពិនិត្យមើលថា តើមានរដ្ឋមន្ត្រីក្រសួងណាខ្លះ ដែលអនុវត្តដោយមានការភ្ញាក់រឮកខ្ពស់។ ចំពោះការដ្ឋានសាងសង់ក៏ដូចគ្នាដែរ ប្រសិនបើមិនទាន់បើកការដ្ឋានសាងសង់នៅឡើយទេ គឺត្រូវផ្អាកសិន ត្រូវដោះស្រាយបញ្ចប់បញ្ហាជំងឺឆ្លងកូវីដ-១៩ (កូរ៉ូណា) ឲ្យចប់ផុតសិន ៗ

## ៩. កម្ពុជាថ្មី៖លោកបណ្ឌិត អ៊ិន ចាន់នី ៖ ការរាតត្បាតនៃវីរុសCovid-19 មិនអាចបង្អាក់ដល់ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនោះទេ




### លោកបណ្ឌិត អ៊ិន ចាន់នី ៖ ការរាតត្បាតនៃវីរុសcovid-19 មិនអាចបង្អាក់ដល់ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនោះទេ

4/3/2020 3:20 Pm ការអភិវឌ្ឍ, ជាតិទូទៅ, ព័ត៌មានជាតិ

like

ភ្នំពេញ ៖ លោកបណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិធនាគារ អេស៊ីលីដា បានមានប្រសាសន៍ថា ការរាតត្បាតនៃវីរុសផ្លូវដង្ហើមថ្មី Covid-19 នឹងមិនអាចបង្អាក់ដល់គម្រោងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងនៅក្នុងទីផ្សារមូលបត្រកម្ពុជានោះទេ។

ថ្លែងប្រាប់អ្នកសារព័ត៌មាន ក្នុងឱកាសផ្សព្វផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ធនាគារអេស៊ីលីដា កាលពីល្ងាចថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ លោកបណ្ឌិត អ៊ិន ចាន់នីបានបន្តថា «ខ្ញុំគិតថាការធ្វើអាជីវកម្មតែងតែគិតពីរឿងហានិភ័យទុករួចជាស្រេចហើយព្រោះវាអាចថាហានិភ័យអាជីវកម្មមានច្រើនមិនមែនមានតែជំងឺឆ្លងនោះទេ តែយើងបានត្រៀមបង្ការជាមុនរួចហើយ អីចឹងការរីកលូតលាស់របស់យើងត្រូវគិតទៅលើវិស័យអ្វីដើម្បីទប់ទល់ទៅនឹងហានិភ័យដែលកំពុងកើតឡើងនាពេលនេះ»។

លោកបានឲ្យដឹងទៀតថា ធនាគារ អេស៊ីលីដា បានដឹងច្បាស់ពីកង្វល់របស់ប្រជាពលរដ្ឋទាក់ទិននឹងជំងឺកូវីដ១៩នេះ តែធនាគារក៏មានវិធានការជាច្រើនដើម្បីធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋទទួលបាននូវផាសុកភាពនិងឈប់បារម្ភបន្តទៀត នៅពេលពួកគាត់មកទទួលសេវានៅតាមសាខាធនាគារនានា។ ជាក់ស្តែងកម្មវិធីនេះ យើងបានត្រួតពិនិត្យដោយការវាស់កម្តៅដល់ភ្ញៀវប្រមាណ៥០០នាក់ដែលបានចូលរួមទៅតាមវិធានការរបស់ក្រសួ ងសុខាភិបាលតែមិនមានភ្ញៀវណាម្នាក់មានកម្តៅលើសនោះទេគឺពួកគាត់មានសុខភាពធម្មតា។

លោកបានបន្ថែមទៀតថា ធនាគារគ្រោងនឹងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីនៅក្នុងផ្សារមូលបត្រកម្ពុជារហូតដល់ជាង៨លាន៧៥ម៉ឺន ភាគហ៊ុន ខណៈភាគហ៊ុនដែលមានស្រាប់មានជាង១៣លានភាគហ៊ុន ដល់សាធារណជន ដោយមានតម្លៃចន្លោះពី១៥.០០០រៀល ដល់១៧.៤០០ រៀល ក្នុងមួយភាគហ៊ុនដែលការកំណត់ដាក់តម្លៃទាំងនេះគឺឈរទៅលើការវាយតម្លៃមួយច្បាស់លាស់រាប់ឆ្នាំមកហើយ។

លោកបានបញ្ជាក់ថា ទ្រព្យសកម្មរបស់ធនាគារមានរហូតដល់៥០ប៊ីលានដុល្លារនិងប្រាក់បញ្ញើសន្សំវិញមានរហូតដល់២៩ប៊ីលានដុល្លារ គិតត្រឹមបំណាច់ឆ្នាំ២០១៩កន្លងមកនេះ បើធៀបទៅនឹងផលទុនជាតិគឺ មានកំណើនខ្ពស់ដែលមានន័យថាមានប្រាក់នៅទំនេរច្រើន។

លោកបានបន្តថា តែយ៉ាងណាក៏ដោយលោកមិនបានបង្ខំឲ្យអ្នកវិនិយោគធ្វើតាមលោកនោះទេ រាល់ការការសម្រេចចិត្តទិញភាគហ៊ុន ឬមិនទិញវាអាស្រ័យលើអ្នកវិនិយោគខ្លួនឯងប៉ុណ្ណោះពោលគឺ ត្រូវមើលព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយនិងធ្វើការពិចារណាឲ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តវិនិយោគឬមិនវិនិយោគ។

ទាក់ទិននឹងការប្រឈមនឹងជំងឺCovid-19នេះដែរលោកបានបញ្ជាក់ថាសន្ទុះនៃការជួញដូរក្នុងផ្សារមូលបត្រកម្ពុជានៅតែមានដំណើរការល្អ បើទោះបីជាពិភពលោកកំពុងប្រឈមនឹងជំងឺCovid-19ក៏ដោយ។ លោកបានមានប្រសាសន៍ថា« ថ្វីត្បិតតែតម្លៃភាគហ៊ុនមានការថយចុះខ្លះ ប៉ុន្តែចំនួននៃការជួញដូរមិនទាន់មានបញ្ហាដែលជាក្តីកង្វល់នៅក្នុងទីផ្សារលក់ភាគហ៊ុនរបស់កម្ពុជានោះឡើយ។

លោកបានបញ្ជាក់ថា ចំនួននៃការជួញដូរភាគហ៊ុនរបស់កម្ពុជា នៅតែមានភាពទាក់ទាញ សម្រាប់វិនិយោគិនព្រោះថាអ្នកវិនិយោគខ្លះគិតថាខណៈដែលភាគហ៊ុនចុះថ្លៃ វាជាឱកាសសម្រាប់ពួកគាត់ទៅវិញក្នុងការងាយស្រួលទិញភាគហ៊ុន ដែលធ្វើឲ្យចំនួនការជួញដូរនៅលើទីផ្សារមិនមានភាពថមថយច្រើនតែតម្លៃហ៊ុនមានការប្រែប្រួលទៅតាមចិត្តសាស្ត្រនៃការជួញដូរនៅក្នុងតំបន់និងជាសកល។

លោកបានបន្តទៀតថា «អីចឹងនេះគឺជាឱកាសដ៏វិសេសវិសាលណាស់សម្រាប់អ្នកវិនិយោគសាធារណៈដើម្បីអាចវិនិយោគក្នុងទីផ្សារមូលបត្រឬភាគហ៊ុនអាចក្លាយជាម្ចាស់របស់ធនាគារអេស៊ីលីដា ព្រោះថាការធ្វើអាជីវកម្មអាចធ្វើដោយខ្លួនឯង ឬធ្វើសន្សំតាមការកំណត់។ ប្រសិនបើបណ្តោយឲ្យឱកាសដ៏ល្អនេះកន្លងផុតនោះ ប្រយ័ត្នមានការស្តាយក្រោយទៅថ្ងៃក្រោយ ព្រោះថាចំណែកហ៊ុនដែលបោះផ្សាយមានទំហំតូចមែនទែន»។

លោកបានបន្ថែមទៀតថា«តែយ៉ាងណាក៏ដោយយើងមិនមានការបង្ខំទេពេលនេះគួរតែបោះផ្សាយលក់ភ្លាមព្រោះទទួលបានអាជ្ញាប័ណ្ណរួចហើយពីគណៈកម្មការមូលបត្រកម្ពុជាតែយើងទុកទៅតាមដំណើរនិងទៅតាមផែនការរបស់យើង។មិនមែនបានភ្លាមបោះពុម្ពលក់ភ្លាមនោះទេដោយទុកឲ្យអ្នកវិនិយោគយកទៅគិតទៅបើមានបំណងវិនិយោគក៏វិនិយោគទៅយើងមិនមានបង្ខិតបង្ខំឡើយ»។

ចំណែកលោក ស៊ូ សុជាតិ អគ្គនាយកគណៈកម្មការមូលបត្រកម្ពុជាដែលមានចូលរួមនៅក្នុងពិធីនាឱកាសដែរនោះ ក៏បានណែនាំឲ្យអ្នកវិនិយោគដែលមានសល់សាច់ប្រាក់តិចឬមធ្យមនេះអាចធ្វើការពិចារណាទិញភាគហ៊ុននៅក្នុងដំណាក់ការដំបូងឬទីផ្សារដំបូង។តែមិនគាំទ្រឲ្យយកផ្ទះឬរបស់របរទៅបញ្ចាំដើម្បីយកមកវិនិយោគនោះទេ។

លោកបានឲ្យដឹងទៀតថា «ប្រសិនបើការប្រឈមនេះទៅបាត់នោះយើងនឹងទទួលបាននូវសក្តានុពលមួយដ៏ធំ ព្រោះយើងមានអ្នកវិនិយោគមួយដែលបានយល់អំពីទីផ្សារដែលពួកគាត់នឹងនៅជាប់ជាមួយយើងហើយក៏ជាទាក់ទាញវិនិយោគពីខាងក្រៅចូលមកកម្ពុជាដែរ»។

សូមបញ្ជាក់ថា ធនាគារ អេស៊ីលីដា ភីអិលស៊ីគឺជាធនាគារទី១ ដែលគ្រោងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅក្នុងអំឡុងខែមេសាខាងមុខនេះ បន្ទាប់ពីមានការឯកភាពពីធនាគារជាតិនៃកម្ពុជា និង គណៈកម្មការមូលបត្រកម្ពុជា។ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារនេះ ត្រូវបានចាត់ទុកជាការលើកទឹកចិត្តដល់វិនិយោគិនរូបវន្តបុគ្គល និងសាធារណជនទូទៅឲ្យចូលរួមក្នុងការវិនិយោគ ដើម្បីផលចំណេញ ឬពង្រីកអាជីវកម្មផ្សេងៗ។

ផ្សារមូលបត្រកម្ពុជា ដែលជាក្រុមហ៊ុនចំណុះរបស់រដ្ឋ ត្រូវបានបើកដំណើរការចាប់តាំងពីឆ្នាំ២០១២ ហើយមកដល់បច្ចុប្បន្ននេះទើបតែមានក្រុមហ៊ុនចំនួន៥ប៉ុណ្ណោះ បានបោះផ្សាយលក់មូលបត្រ មានដូចជាកំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត កំពង់ផែស្វយ័តភ្នំពេញ ក្រុមហ៊ុន ហ្គ្រេនធ្វីន និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ៕

## ១០. រស្មីកម្ពុជា៖ធនាគារពិភពលោក ផ្តល់ហិរញ្ញវត្ថុបន្ទាន់ចំនួន១២ប៊ីលានដុល្លារសម្រាប់ជួយដល់ការឆ្លើយតបទៅនឹងការសាយភាយជំងឺ ខូវីដ-១៩ នៅតាម ប្រទេស កំពុងអភិវឌ្ឍន៍



***ដោយៈសុផល/ភ្នំពេញ ៖*** ស្របពេល ដែលជាង ៦០ប្រទេស មានការរាលដាលជំងឺ ខូវីដ-១៩ ក្រុមធនាគារពិភពលោក កំពុងដាក់ចេញកញ្ចប់ ហិរញ្ញប្បទានជំហានដំបូងមួយដែលមានទឹកប្រាក់១២ប៊ីលានដុល្លារសម្រាប់ជាវិធានការបន្ទាន់ ដើម្បីជួយ ដល់បណ្តាប្រទេសនានា ក្នុង ការលៃលកជាមួយ ផលប៉ះទង្គិចផ្នែកសុខាភិបាល និង សេដ្ឋកិច្ច ដោយសារតែការផ្ទុះជំងឺនេះ លើសាកលលោក។ នេះបើតាមសេចក្តីប្រកាសពត៌មានរបស់ធនាគារពិភពលោកកាលពីរសៀលថ្ងៃទី៤ខែមីនា ឆ្នាំ២០២០។

កញ្ចប់ហិរញ្ញប្បទាននេះ មានគោលដៅជួយ ប្រទេសសមាជិក ឱ្យមានលទ្ធភាពចាត់វិធានការមាន ប្រសិទ្ធភាព តាមភាពជាក់ស្តែង ក្នុង ការ ឆ្លើយតប ក៏ដូចជាក្នុង ការកាត់បន្ថយ ផលប៉ះទង្គិចធ្ងន់ធ្ងរ ដែល បង្ក ដោយ ជំងឺ ខូវីដ-១៩ (ឬវិរុសកូរ៉ូណា)។

សេចក្តីប្រកាសនេះបានឱ្យដឹងថាតាមរយៈ កញ្ចប់ វិធានការពន្លឿនហិរញ្ញប្បទាននេះ ក្រុមធនាគារពិភពលោក នឹង ជួយ បណ្តា ប្រទេស ពង្រឹង ប្រព័ន្ធ សុខាភិបាល របស់ ខ្លួន រួមក្នុងនោះមាន លទ្ធភាពកាន់តែប្រសើរក្នុងការទទួល បាន សេវាសុខា ភិបាល ដើម្បីការពារប្រជាជនពី ការ រាលដាល នៃជំងឺនេះ, ពង្រឹង ការ អង្កេតតាមដាន ជំងឺ, បង្កើន កិច្ច អន្តរាគមន៍ សុខាភិបាលសាធារណៈ, និង សហការជាមួយ វិស័យឯកជន ដើម្បីឈាន ទៅ កាត់ បន្ថយ ផល ប៉ះអង្គិច របស់ជំងឺនេះទៅលើសេដ្ឋកិច្ច។

កញ្ចប់ហិរញ្ញប្បទាននេះអាចដកយកទៅប្រើ ប្រាស់ បាន តាម រយៈយន្តការ “សមាគមអភិវឌ្ឍន៍អន្តរជាតិ/IDA”, “ធនាគារអន្តរជាតិសម្រាប់ការកសាងឡើងវិញ និង ការ អភិវឌ្ឍ/IBRD” និង “សាជីវកម្ម ហិរញ្ញវត្ថុ អន្តរជាតិ/IFC” ក្រោមកិច្ច សម្រប សម្រួល គ្នា ក្នុង កម្រិត សាកល ដើម្បីជួយ អន្តរគមន៍ ដល់ ការ ឆ្លើយ តប នៅតាម ប្រទេសនានា។

---

កញ្ចប់ហិរញ្ញប្បទាន សម្រាប់ ទ្រទ្រង់ការឆ្លើយតបជំងឺ ខូវីដ-១៩ នេះ នឹង មានធនធាន ដំបូង ១២ប៊ីលានដុល្លារអាមេរិក — ក្នុងនោះ ៨ប៊ីលានដុល្លារជាចំនួន ថ្មី — ដែល អាច យក ទៅ ប្រើ ប្រាស់ បាន តាម យន្តការ ពន្លឿន។ ក្នុង កញ្ចប់ នេះ រួមមានដល់ ទៅ ២,៧ប៊ីលានដុល្លារ ជា ហិរញ្ញប្បទាន ថ្មី ពី IBRD; ១,៣ប៊ីលានដុល្លារ ពី IDA ដែលត្រូវ បានបំពេញបន្ថែមពីការធ្វើ អាទិភាពឡើងវិញនូវ ថវិកា ២ប៊ីលានដុល្លារដែល មាន ស្រាប់ នៅក្នុង កញ្ចប់កម្មវិធី របស់ ធនាគារពិភពលោក និង ៦ប៊ីលានដុល្លារ មក ពី IFC ក្នុងនោះរួមមាន ២ប៊ីលាន ដុល្លារ ពីមូលនិធិទ្រទ្រង់ពាណិជ្ជកម្ម ដែល មាន ស្រាប់ ផង ដែរ។ កញ្ចប់ហិរញ្ញប្បទាននេះក៏មានអមមកជាមួយនូវ ការ ផ្តល់ ប្រឹក្សា គោលនយោបាយ និង ជំនួយបច្ចេកទេស ដែលផ្អែកលើ ជំនាញឯកទេស លើសាកលលោក និង ចំណេះដឹងនៅក្នុង ស្រុក តាម ប្រទេសនីមួយៗ ដែរ។

លោក ដេវិដ ម៉ាលប៉ាស់ ប្រធាន ធនាគារពិភពលោក មាន ប្រសាសន៍ថា៖ «ពេលនេះ យើងកំពុងតែខិតខំធ្វើការឆ្លើយតបឱ្យ បាន រហ័ស រហួន និង ដោយ ភាពបត់បែន ដោយ ផ្អែកលើតម្រូវការ នៅតាម ប្រទេស ក្នុង ការ លៃលក ជាមួយ ការ សាយភាព របស់ ជំងឺ ខូវីដ-១៩។ នៅក្នុងនេះ យើង មាន វិធានការធ្វើ ហិរញ្ញប្បទានបន្ទាន់, ការផ្តល់ ប្រឹក្សា គោលនយោបាយ និង ជំនួយបច្ចេកទេស ដោយ ប្រើ ប្រាស់ ឧបករណ៍ និង ជំនាញឯកទេស ដែលធនាគារពិភពលោកមាន ស្រាប់ ដើម្បី ជួយ ប្រទេសនានា ក្នុង ការ ឆ្លើយ តប ទៅ នឹង វិបត្តិមួយនេះ។»

កញ្ចប់ហិរញ្ញប្បទាននេះ នឹង ផ្តល់ ជំនួយឥតសំណង និង ឥណទានមានការប្រាក់ទាប ពី IDA ដល់ ប្រទេស មាន ចំណូលទាប និង ឥណទានពី IBRD សម្រាប់ ប្រទេស មានចំណូលមធ្យម ដោយ ប្រើ ប្រាស់ ឧបករណ៍ ប្រតិបត្តិការ របស់ ធនាគារ លើមូលដ្ឋានពន្លឿនការ អនុម័ត លើ ការ ផ្តល់ ហិរញ្ញប្បទាន។ សាជីវកម្ម ហិរញ្ញវត្ថុ អន្តរជាតិ (International Finance Corporation) ដែលជាសាខា វិស័យឯកជន របស់ ធនាគារពិភពលោក នឹង ផ្តល់ ការ គាំទ្រ ចាំបាច់ ដល់ អតិថិជន របស់ ខ្លួន ដើម្បីធ្វើយ៉ាងណាឱ្យ ពួកគេអាចបន្តប្រតិបត្តិការអាជីវកម្ម

និង រក្សា ការ ងារ បាន តទៅទៀត។

ធនាគារពិភពលោកនឹង មាន ចង្កោម អន្តរាគមន៍ ផ្សេងទៀត សម្រាប់ ជួយ ពង្រឹង សេវា សុខាភិបាល និង ការថែទាំសុខភាព បឋម, ពង្រឹង ការ អង្កេត តាម ដាន ជំងឺ និង ការ រាយការណ៍អំពី ស្ថាន ភាពជំងឺ, ជំរុញ ការ ចូល ពាក់ ព័ន្ធ របស់ សហគមន៍ ដើម្បី រក្សា ឱ្យ បាន នូវ ទំនុក ចិត្ត របស់ សាធារណៈ, និង ធ្វើ ឱ្យ កាន់តែប្រសើរឡើងនូវ លទ្ធភាព របស់ អ្នក ជំងឺក្រីក្រ ក្នុង ការ ទទួល បាន ការ ព្យាបាល ជំងឺ។ ធនាគារពិភពលោកក៏នឹង ផ្តល់ ប្រឹក្សាគោលនយោបាយ និង ជំនួយ បច្ចេកទេស ដល់ បណ្តា ប្រទេស នៅ ក្នុង ការ រក ជំនាញ ឯកទេស លំដាប់សាកល សម្រាប់ ឆ្លើយ តប ក្នុង ស្ថាន ភាពបច្ចុប្បន្ន។

សាជីវកម្ម ហិរញ្ញវត្ថុ អន្តរជាតិ (IFC) នឹងធ្វើ ការ ជាមួយ ធនាគារពាណិជ្ជកម្មជាអតិថិជនរបស់ខ្លួន ក្នុង ទិសដៅ ពង្រីក សេវា ផ្តល់ ហិរញ្ញប្បទានពាណិជ្ជកម្ម និង ទុន សម្រាប់ ប្រតិបត្តិការ។ ស្ថាប័នមួយនេះក៏នឹង ផ្តល់ ការគាំពារផ្ទាល់ ដល់ អតិថិជន សាជីវកម្ម របស់ ខ្លួន ផងដែរ — ដោយ ផ្តោតសំខាន់ លើ វិស័យ យុទ្ធសាស្ត្រ រួម មាន ផ្នែក បរិក្ខារពេទ្យ និង ថ្នាំពេទ្យ — ដើម្បីធ្វើយ៉ាងណា ឱ្យ ច្រវាក់ ផ្គត់ផ្គង់មាន ស្ថិរភាព និង កំហិតហានិភ័យ ដល់ អ្នក ប្រើ ប្រាស់ ឱ្យនៅទាបបំផុត។ ដំណោះស្រាយទាំងនេះនឹង ត្រូវ បាន ពង្រឹង បន្ថែម ទៀត ដោយ បទពិសោធន៍ របស់ ព្រឹត្តិការណ៍ ប្រហាក់ ប្រហែលនេះដែលធ្លាប់ មានពីមុន មក អម ដោយ គោលដៅ ឈាន ទៅ កាត់ បន្ថយ ផលប៉ះទង្គិច អវិជ្ជមានផ្នែកសេដ្ឋកិច្ច និង សង្គម ដោយសារជំងឺ ខូវីដ-១៩ នៅទូទាំងសាកលលោក។

ប្រទេសទាំងអស់ប្រឈមហានិភ័យ និង ភាពងាយរងគ្រោះ ដោយសារជំងឺ ខូវីដ-១៩ ក្នុងកម្រិតខុសៗគ្នា ហើយដូច្នេះ ក៏មានតម្រូវការ ឱ្យ មានការឧបត្ថម្ភគាំទ្រ ក្នុងផ្សេងៗគ្នាដែរ។ ធនាគារពិភពលោកនឹង ធ្វើ អាទិភាពការគាំទ្រ សម្រាប់ ប្រទេស ក្រីក្រ និង ប្រទេសទាំងឡាយណាដែល ជួបហានិភ័យខ្ពស់ ប៉ុន្តែខ្វះសមត្ថភាពក្នុង ការឆ្លើយតប។ ក្នុងខណៈដែលជំងឺ ខូវីដ-១៩ នៅតែបន្តសាយភាព ហើយ ផលប៉ះទង្គិច របស់ វា បេះ តែវិវត្ត ប្រែប្រួល ធនាគារពិភពលោក នឹង ធ្វើ ត្រៀមខ្លួន កែសម្រួល វិធីសាស្ត្រ និង ធន ធាន របស់ ខ្លួន គ្រប់កាលៈទេសៈ តាម ភាពចាំបាច់។

ធនាគារពិភពលោក កំពុង តែ សកម្មក្នុង ការ សហការជាមួយបណ្តា ស្ថាប័នអន្តរជាតិ និង អាជ្ញាធរតាម ប្រទេស នៅ ក្នុង ការ ជួយ សម្របសម្រួល វិធានការ ឆ្លើយ តប ជាលក្ខណៈសាកលទៅនឹងជំងឺនេះ៕/B

## ១១. រស្មីកម្ពុជាៈថៃរឹតត្បិតអ្នកដំណើរទៅពី៩ប្រទេស ហើយអ្នករំលោភអាចជាប់គុកនិងពិន័យប្រាក់



មន្ត្រីសុខាភិបាលថៃបាននិយាយនៅថ្ងៃពុធទី០៤ខែមីនាថា ពួកអ្នកទេសចរនិងជនជាតិថៃដែលវិលត្រឡប់មកប្រទេសថៃពីប្រទេស៩ដែលកំពុងផ្ទុះជម្ងឺឆ្លងCOVID-19 ដោយរួមទាំងប្រទេសសិង្ហបុរីត្រូវបានណែនាំឱ្យស្ថិតនៅដាច់ដោយឡែករយៈពេល២សប្តាហ៍និងរាយការណ៍ពីអំពីទីកន្លែងរស់នៅរបស់ពួកគេទៅក្រុមអាជ្ញាធរថៃ។

អ្នកនាំពាក្យក្រសួងសុខាភិបាលថៃ បាននិយាយថាអ្នកទេសចរដែលមិនអាចបង្ហាញអាសយដ្ឋានឱ្យបានត្រឹមត្រូវនៅប្រទេសថៃ នឹងត្រូវបញ្ជូនចេញទៅកន្លែងដែលពួកគេមក។

ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបាននិយាយថា ការរំលោភលើបទបញ្ជាចត្តាឡីស័ក(ការដាក់នៅដោយឡែក)នេះនឹងត្រូវបានដាក់ទោសឱ្យជាប់គុកមួយឆ្នាំ ឬ ពិន័យជាប្រាក់១០០.០០០ បាត (ជាង៣.០០០ដុល្លារ)។

ច្បាប់នេះនឹងចូលជាធរមានក្រោយមានការពិនិត្យឡើងវិញប្រទេសនិងកន្លែងដែលមានហានិភ័យខ្ពស់ និងវាត្រូវបោះផ្សាយក្នុងរាជកិច្ច។

ប្រទេសសិង្ហបុរីត្រូវបានចុះបញ្ជីក្នុងចំណោមប្រទេសទាំង៩ ដែលមានហានិភ័យខ្ពស់នៅក្នុងសេចក្តីប្រកាសរបស់ក្រសួងសុខាភិបាលថៃកាលពីថ្ងៃអង្គារប៉ុន្តែក្រោយមកបញ្ជីនេះត្រូវបានដកវិញនៅមុនពេលការណែនាំមួយត្រូវបានធ្វើឡើងម្តងទៀតនៅថ្ងៃពុធ។

ប្រទេសនិងតំបន់ចំនួន៨ ទៀតគឺរួមមាន ប្រទេសចិន (រួមទាំងក្រុងហុងកុងនិងម៉ាកាវ) ជប៉ុន កូរ៉េខាងត្បូង កោះតៃវ៉ាន់ អាល្លឺម៉ង់ បារាំង អ៊ីតាលីនិង អ៊ីរ៉ង់។

នៅពេលនេះ ប្រទេសថៃ មានករណីឆ្លងវីរុសនេះ ចំនួន៤៣ករណីនិង មានករណីស្លាប់មនុស្សម្នាក់ជនជាតិថៃភេទប្រុស អាយុ៣៥ឆ្នាំ ដោយសារវីរុសនេះ៕ប្រែសម្រួល៖*សុខា/sn*



## ១២. រស្មីកម្ពុជា៖ WHO ៖ កង្វះប្រព័ន្ធថែទាំសុខភាព និង ការផ្ទុះវីរុសកូរ៉ូណានៅអ៊ីតាលី អ៊ីរ៉ង់ និងកូរ៉េខាងត្បូង ជាក្តីបារម្ភខ្លាំងបំផុត


រស្មីកម្ពុជា







ព័ត៌មានអន្តរជាតិ

# WHO ៖ កង្វះប្រព័ន្ធថែទាំសុខភាព និង ការផ្ទុះវីរុសកូរ៉ូណានៅអ៊ីតាលី អ៊ីរ៉ង់ និងកូរ៉េខាងត្បូង ជាក្តីបារម្ភខ្លាំងបំផុត

March 4, 2020, 3:40 PM

63






អ្នកនាំពាក្យរបស់អង្គការសុខភាពពិភពលោក (WHO) លោកស្រីវេជ្ជបណ្ឌិត ម៉ាហ្គារ៉េត ហារីស ទើបតែវិលត្រឡប់មកទីក្រុងហ្សឺណែវវិញដើម្បីធ្វើការជាមួយក្រុមការងារទប់ទល់នឹងវីរុសកូរ៉ូណា។

លោកស្រីបានត្រឡប់មកពីសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដែលកំពុងប្រឈមនឹងការផ្ទុះឡើងនៃជំងឺអេបូឡា។

លោកស្រីបានប្រាប់កាសែត The Straits Times ថា “យើងមានការផ្ទុះឡើងនៃជំងឺអេបូឡាដ៏អាក្រក់នៅទីនោះ។ វាបានបន្តកើតឡើងអស់រយៈពេលមួយឆ្នាំកន្លះហើយ ហើយមានមនុស្សច្រើនណាស់បានស្លាប់ គឺចំនួន ២.៤០០ នាក់”។

លោកស្រីបាននិយាយនៅក្នុងបទសម្ភាសន៍តាមទូរស័ព្ទពីទីក្រុងហ្សឺណែវថា “ប៉ុន្តែវីរុសកូរ៉ូណាបានសម្លាប់មនុស្សជាច្រើនក្នុងរយៈពេលតែប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ។ នោះគឺជាការប្រៀបធៀបខ្លះនៃភាពធ្ងន់ធ្ងរនិងភាពជំពេងនៃការបំផ្លិចបំផ្លាញនៃវីរុសនេះ”។

អង្គការ WHO និយាយកាលពីថ្ងៃអង្គារថា ប្រហែល ៣,៤ ភាគរយនៃជនរងគ្រោះនៃវីរុសកូវីដ១៩បានស្លាប់ដោយសារវីរុសនេះនៅទូទាំងពិភពលោក។ បើប្រៀបធៀប ជំងឺផ្តាសាយតាមរដូវជាទូទៅសម្លាប់មនុស្សតិចជាង ១ ភាគរយនៃអ្នកឆ្លងទាំងអស់។

រដ្ឋលេខាធិការអង្គការសុខភាពពិភពលោក លោក ថេដ្រូស អាដាណុម ហ្គេប្រេយ៉េស៊ូស បាននិយាយថា “ភាពខុសគ្នាធំទីពីរគឺថា កូវីដ១៩បង្កឱ្យមានជំងឺធ្ងន់ធ្ងរជាងជំងឺផ្តាសាយតាមរដូវ។

ខណៈមនុស្សជាច្រើននៅទូទាំងពិភពលោកបានពង្រឹងប្រព័ន្ធភាពស៊ាំទៅនឹងជំងឺផ្តាសាយតាមរដូវ វីរុសកូវីដ១៩គឺជាមេរោគថ្មីមួយដែលគ្មាននរណាម្នាក់មានប្រព័ន្ធភាពស៊ាំទប់ជាមួយវានោះទេ”។

លោកស្រីវេជ្ជបណ្ឌិតហារីសបានចង្អុលទៅប្រទេសទាំង ៣ ដែលគួរឱ្យបារម្ភបំផុតគឺ អ៊ីតាលី អ៊ីរ៉ង់ និងកូរ៉េខាងត្បូង។

លោកស្រីបាននិយាយថា “ការព្រួយបារម្ភបំផុតរបស់យើងគឺប្រទេសទាំងបី ដែលមានការផ្ទុះឡើងយ៉ាងខ្លាំងនៃវីរុសកូរ៉ូណា និងកំពុងជួបការលំបាកក្នុងការទប់ទល់នឹងការផ្ទុះឡើងទាំងនេះ។ រឿងមួយទៀតដែលធ្វើឱ្យយើងព្រួយបារម្ភគឺថា វាជាវីរុសដ៏កាចសាហាវ។ ដូច្នេះដំបូងឡើយមនុស្សនិយាយថា វាជាអត្រាស្លាប់ ១ ភាគរយប៉ុណ្ណោះ ប៉ុន្តែឥឡូវយើងឃើញមានមនុស្សស្លាប់ច្រើនឡើង”។

លោកស្រីបាននិយាយថា ជារៀងរាល់ថ្ងៃមនុស្សកាន់តែច្រើនឡើងត្រូវការ “ការថែទាំសុខភាពនិងថែទាំវេជ្ជសាស្ត្រកម្រិតខ្ពស់បំផុតក្នុងរយៈពេលយូរ សម្រាប់ពីរទៅបីសប្តាហ៍” ដោយដាក់សម្ពាធសូម្បីនៅក្នុងប្រទេសដែលមានប្រព័ន្ធសុខភាពសាធារណៈខ្លាំងក្លា៕ ដោយៈ កញ្ញាដាលីស

## ១៣. រស្មីកម្ពុជា៖ វេជ្ជបណ្ឌិតម្នាក់ទៀតនៅក្រុងវូហាន ស្លាប់ដោយឆ្លងវីរុសCOVID-19

រស្មីកម្ពុជា



ក្នុងប្រទេស អន្តរជាតិ កម្សាន្ត សុខភាព បច្ចេកវិទ្យា-វិទ្យាសាស្ត្រ កីឡា ចំណេះដឹងទូទៅ ប្លែកៗ ស្រាវជ្រាវ បទវិភាគ

ព័ត៌មានអន្តរជាតិ

### វេជ្ជបណ្ឌិតម្នាក់ទៀតនៅក្រុងវូហាន ស្លាប់ដោយឆ្លងវីរុស COVID-19

March 4, 2020, 3:24 PM    76




វេជ្ជបណ្ឌិតមុី ហ្សុងមីញ គ្រូពេទ្យជំនាញជំងឺភ្នែកនៅមន្ទីរពេទ្យក្រុងវូហាននៅខេត្តហ៊ូប៉ី ប្រទេសចិនបានស្លាប់ ដោយសារឆ្លងវីរុសCOVID-19 កាលពីថ្ងៃអង្គារទី០៣ខែមីនា។ នេះបើយោងតាមសេចក្តីបញ្ជាក់ពីមន្ទីរពេទ្យ។

វេជ្ជបណ្ឌិត អាយុ៥៧ឆ្នាំនេះ បានឆ្លងវីរុស នៅពេលព្យាបាលពួកអ្នកជំងឺដែលមានវីរុសCOVID-19នេះ។

លោកមុី ហ្សុងមីញ អនុប្រធានផ្នែកចក្ខុរោគនៃមន្ទីរពេទ្យនេះជាមិត្តរួមការងាររបស់ វេជ្ជបណ្ឌិតលី វេនលៀងគឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្ស៨នាក់ដែលបានព្យាយាមព្រមានអំពីវីរុសនេះនៅពេលវាបានកើតឡើងជាលើកដំបូងនៅទីក្រុងវូហាន ។

វេជ្ជបណ្ឌិតលី វេនលៀង បានស្លាប់ដោយសារវីរុសនេះ កាលពីដើមខែកុម្ភៈ។

វេជ្ជបណ្ឌិតម្នាក់នៅមន្ទីរពេទ្យនេះ បាននិយាយថា “វេជ្ជបណ្ឌិត មុី ហ្សុងមីញបានឆ្លងវីរុសនេះ កាលពីពាក់កណ្តាលខែមករាហើយស្ថានភាពជំងឺរបស់គាត់បានចាប់ផ្តើមធ្ងន់ធ្ងរនៅថ្ងៃទី១១ខែកុម្ភៈ៕ប្រែសម្រួល៖ *សុខា/sn*

# ១៤.រស្មីកម្ពុជា៖ មហាសេដ្ឋីចិនជែក ម៉ា បរិច្ចាគម៉ាស់មុខ១លានដល់ជប៉ុន ដែលកំពុងរងគ្រោះដោយវីរុសកូរ៉ូណា


រស្មីកម្ពុជា






ព័ត៌មានអន្តរជាតិ

## មហាសេដ្ឋីចិនជែក ម៉ា បរិច្ចាគម៉ាស់មុខ១លានដល់ជប៉ុន ដែលកំពុងរងគ្រោះដោយវីរុសកូរ៉ូណា

March 4, 2020, 2:52 PM


90





បុរសមានបំផុតម្នាក់របស់ចិនគឺលោកជែក ម៉ា សហស្ថាបនិកក្រុមហ៊ុនពាណិជ្ជកម្មអេឡិចត្រូនិចយក្ស Alibaba ដែលមានមូលដ្ឋាននៅទីក្រុងហាងចូវ បានបរិច្ចាគម៉ាស់មុខចំនួនមួយលានដល់ជប៉ុន។

លោកបាននិយាយថានេះជាថ្នូរនឹងជំនួយសប្បុរសធម៌ដែលជប៉ុនបានផ្តល់ជូនដល់ប្រទេសចិន នៅពេលដែលប្រទេសចិនរងការវាយប្រហារដោយវីរុសកូរ៉ូណាកាលពី ២០ ថ្ងៃមុន។

ទីភ្នាក់ងារសារព័ត៌មានស៊ីនហួបានរាយការណ៍ថា មជ្ឈដ្ឋាននានាក្នុងប្រទេសជប៉ុនបានប្រមូលនិងបរិច្ចាគឈុតការពារចំនួន ១២៥.០០០ ដល់ទីក្រុងនានាទូទាំងប្រទេសចិន។

អង្គការមូលនិធិជែកម៉ានិងអង្គការមូលនិធិអាលីបាបា បានប្រកាសកាលពីថ្ងៃចន្ទ ទី២ មីនាថា ម៉ាស់មុខទាំងនេះនឹងត្រូវបរិច្ចាគទៅប្រទេសជប៉ុនដើម្បីជួយកាត់បន្ថយទុក្ខលំបាកក្នុងគ្រាផ្ទុះរោគរាតត្បាតនេះ។

លោកម៉ាបាននិយាយនៅលើគណនី Weibo របស់គាត់ដោយដកស្រង់ពាក្យចាស់បុរាណចិន យ៉ាងដូច្នេះថា “ដូចជួរភ្នំដ៏វែងលាតសន្ធឹងនៅចំពោះមុខអ្នកនិងខ្ញុំ សូមចែករំលែកផ្លូវដើរនិងការលំបាកជាមួយគ្នា។ យើងសង្ឃឹមថាអ្វីៗនឹងបានធូរស្រាលក្នុងពេលឆាប់ៗ”។

ម៉ាស់ទម្ងន់ ៤៩,៤ តោនត្រូវបានដឹកដោយក្រុមហ៊ុនអាកាសចរណ៍ចិនខាងកើត ហើយបានទៅដល់ទីក្រុងតូក្យូកាលពីថ្ងៃអង្គារទី៣មីនា៕ ដោយ៖ កញ្ញាដាលីស

# ១៥. រស្មីកម្ពុជា៖ នារីយូនណានអាយុ២២ ឆ្នាំ ក្លាយជាអ្នកបរិច្ចាគឈាមទី១ នៅខេត្តយូនណាន ក្រោយជាសះស្បើយពីជំងឺរលាកសួតបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី

រស្មីកម្ពុជា






ព័ត៌មានអន្តរជាតិ

## នារីយូនណានអាយុ២២ ឆ្នាំ ក្លាយជាអ្នកបរិច្ចាគឈាមទី១ នៅខេត្តយូនណានក្រោយជាសះស្បើយពីជំងឺរលាកសួតបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី

March 4, 2020, 10:22 AM

83




នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០២០ កញ្ញាលី លីង(ឈ្មោះក្លែង) ដែលទទួលការព្យាបាលជំងឺរលាកសួតបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មីនិងបានជាសះស្បើយនៅមន្ទីរពេទ្យព្យាបាលជំងឺឆ្លងលេខ១ ខេត្តយូនណាន បានបរិច្ចាគឈាមប្រភេទបេ ចំនួន ៤០០ មីល្លិលីត្រដោយស្ម័គ្រចិត្តហើយបានក្លាយទៅជាអ្នកបរិច្ចាគឈាមទី១ នៅខេត្តយូនណានក្រោយជាសះស្បើយពីជំងឺរលាកសួតដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី។

កញ្ញាលី លីង មកពីក្រុងអ៊ូហាននៃខេត្តហ៊ូប៉ី។ ក្រោយពីកើតជំងឺរលាកសួតដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី លី លីង ក៏ចាប់ផ្តើមទទួលការព្យាបាលនៅក្រុងគុនមីង។ ឆ្លងតាមរយៈការព្យាលបាលយ៉ាងហ្មត់ចត់ពីគ្រូពេទ្យជំនាញកម្តៅខ្លួនរបស់ លី លីងមានភាពប្រក្រតីក្នុងរយៈពេល ១០ថ្ងៃជាប់ ហើយគ្មានអាការមិនប្រក្រតីក្នុងប្រព័ន្ធដកដង្ហើម បំណែកលទ្ធផលនៃការថតCT ក៏មានភាពប្រក្រតីឡើងវិញ។ ការធ្វើតេស្តអំពីវីរុសកូរ៉ូណា២ ដងសុទ្ធតែមានលទ្ធផល“-” ហើយស្របនឹងស្តង់ដារអំពីការចេញពីមន្ទីរពេទ្យ។ ក្រោយពីធ្វើការពិនិត្យនិងពិគ្រោះពិភាក្សាគ្នាអ្នកជំនាញការបានសម្រេចឱ្យកញ្ញាលី លីង ចេញពីមន្ទីរពេទ្យ ។

ដើម្បីផ្តល់ក្តីសង្ឃឹមនិងជួយព្យាបាលជំងឺឱ្យអ្នកជំងឺកាន់តែច្រើនមជ្ឈមណ្ឌលឈាមក្រុងគុនមីងខេត្តយូនណានបានធ្វើការរៀបចំបន្ទាន់រយៈពេល២៤ ម៉ោង ហើយបានយល់ព្រមឱ្យលី លីង ទៅបរិច្ចាគឈាមដោយឈរលើមូលដ្ឋាននៃការថែរក្សាសុខភាពនិងធានាគុណភាពឈាមរបស់អ្នកបរិច្ចាគឈាម។

គួរបញ្ជាក់ថា ឈាមរបស់អ្នកកើតជំងឺរលាកសួតដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មីនឹងអាចត្រូវប្រើប្រាស់ក្នុងការព្យាបាលអ្នកជំងឺកម្រិតធ្ងន់។ នេះជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺនិងបន្ថយអត្រាស្លាប់នៃអ្នកជំងឺ ពីព្រោះគ្រូពេទ្យអាចប្រើសមាសធាតុទប់ទល់នឹងមេរោគក្នុងឈាមរបស់អ្នកជាសះស្បើយសម្រាប់បន្ថយចំនួនមេរោគក្នុងខ្លួនអ្នកជំងឺផ្សេងដើម្បីព្យាបាលអ្នកជំងឺនោះ ។គិតមកដល់ថ្ងៃទី ១៩ ខែកុម្ភៈ អ្នកជំងឺ ២ រូបនៅខេត្តយូនណាន ដែលបានជាសះស្បើយពីជំងឺរលាកសួត បង្កដោយវីរុសកូរ៉ូណាប្រភេទថ្មីបាន

ទៅបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ៕ ដោយតាង សៀវធី និង តៃ ជីនហ្វ/Ha



## ១៦. រស្មីកម្ពុជា៖ ក្នុងបំណងស្តារជើងហោះហើរឡើងវិញ សំបុត្រយន្តហោះ១២ដុល្លារ អាចជិះហោះនៅទូទាំងប្រទេសចិន







ដំណឹងអន្តរជាតិ ប្លែកៗ

# ក្នុងបំណងស្តារជើងហោះហើរឡើងវិញ សំបុត្រយន្តហោះ១២ដុល្លារ អាចជិះហោះនៅទូទាំងប្រទេសចិន

March 4, 2020, 8:40 AM

333






ក្រុមហ៊ុនអាកាសចរណ៍ចិនកំពុងផ្តល់តម្លៃសំបុត្រទាបបំផុត ដែលគេច្រើននិយាយថា”ថោកដូចព្រលឹត” ខណ: ដែលក្រុមហ៊ុនអាកាសចរណ៍ចាប់ផ្តើមស្តារជើងហោះហើរឡើងវិញបន្ទាប់ពីកាត់បន្ថយការហោះហើរស្ទើរទាំងស្រុងដោយសារការផ្ទុះឡើងនៃវីរុសCovid-19។

សំបុត្រយន្តហោះហោះត្រង់ពីទីក្រុងសៀងហៃ ទៅទីក្រុងឆឹងឌូ (នៅប្រទេសចិន)តាមយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍Juneyao Airlines Co នៅថ្ងៃទីសៅរ៍ទី៧ខែមីនានេះគឺតម្លៃតែ៩០ យ័ន(ជាង១២ដុល្លារអាម៉េរិក)ប៉ុណ្ណោះ ដោយបូកពន្ធ៥០ យ័ន។ ចម្ងាយពីពីទីក្រុងសៀងហៃទៅទីក្រុងឆឹងឌូ គឺហោះហើររយ:ពេល៣ម៉ោងកន្លះ ។

ក្រុមហ៊ុនអាកាសចរណ៍ចិនកំពុងបន្ថែមជើងហោះហើរដើម្បីទទួលបានអ្នកដំណើរ៣លាននាក់តាមការគ្រោងទុកនៅសប្តាហ៍នេះ ជាពិសេសសម្រាប់ការហោះហើរក្នុងស្រុក។ នេះបើយោងតាមអង្គការ អាកាសចរណ៍ពិភពលោកOAG Aviation Worldwide៕ប្រែសម្រួល៖*សុខា/sn*

## ១៧. ដើមអម្ពិលៈកងទ័ពរំដោះប្រជាជនចិន ផ្អាកធ្វើសមយុទ្ធរួមគ្នា ទ្រង់ទ្រាយធំប្រចាំឆ្នាំ




បរទេស៖ កងកម្លាំងប្រដាប់អាវុធ របស់ប្រទេសចិន បានផ្អាកការធ្វើសមយុទ្ធរួមគ្នា ប្រចាំឆ្នាំនៅតំបន់ស្វយ័ត Inner Mongolia ចំពេលមានការផ្ទុះឡើង នូវមេរោគថ្មី COVID-19 ហើយគ្រឿងឧបករណ៍ដឹកជញ្ជូន កំពុងត្រូវបានប្រើជំនួស ដើម្បីប្រយុទ្ធប្រឆាំង នឹងការផ្ទុះឡើង នៅកណ្តាលទីក្រុងវូហាន ។ ទោះយ៉ាងណាក៏ដោយអង្គភាព ព្រំដែន និងការហ្វឹកហាត់ តែមួយសាខា នឹងមិនរងផលប៉ះពាល់ទេ។

យោងតាមសារព័ត៌មាន Sputnik ចេញផ្សាយកាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ បានឱ្យដឹងថា នៅក្នុងសន្និសីទកាសែតខ្លីមួយ ដោយការិយាល័យព័ត៌មាន នៃក្រុមប្រឹក្សារដ្ឋរបស់រដ្ឋចិន (SCIO) ប្រធានផ្នែកដឹកជញ្ជូន របស់កងទ័ពរំដោះប្រជាជនចិន (PLA) បាននិយាយ ថា សមយុទ្ធប្រចាំឆ្នាំប្រចាំឆ្នាំទ្រង់ទ្រាយធំ ដែលជាធម្មតា ត្រូវបានធ្វើឡើងនៅឯមូលដ្ឋាន បណ្តុះបណ្តាល Zhurihe នៅក្នុងតំបន់ស្វយ័ត Inner Mongolia នឹងត្រូវផ្អាក ។

ជំនួសមកវិញ គឺ PLA បានបញ្ជូនបុគ្គលិកពេទ្យជាង ១០,០០០ នាក់ ព្រមទាំងយន្តហោះដឹកជញ្ជូន និងរថយន្ត ទៅខេត្ត Hubei ដែលជាចំណុចនៃការផ្ទុះឡើងនៃវីរុសឆ្លង ដើម្បីដឹកសម្ភារៈតាមសាឡាងទៅក្នុងស្រុក ដែលត្រូវបានគេកាត់ផ្តាច់ ។ នេះបើតាម នាយកដ្ឋានគាំទ្រភ័ស្តុភារនៃគណៈកម្មការយោធាកណ្តាល (CMC) បានបញ្ជាក់កាលពីថ្ងៃច័ន្ទ។

ប្រែសម្រួល: ណៃ តុលា

## ១៩. ដើមអម្ពិល៖ នាយករដ្ឋមន្ត្រីថៃ និងមន្ត្រីគណៈរដ្ឋមន្ត្រី នឹងនាំគ្នាបរិច្ចាគប្រាក់ខែ ដើម្បីប្រយុទ្ធប្រឆាំង នឹងមេរោគ Covid-19




បរទេស៖ អ្នកនាំពាក្យរដ្ឋាភិបាលថៃ លោកស្រី Narumon Pinyosinwat បាននិយាយកាលពីថ្ងៃអង្គារថា នាយករដ្ឋមន្ត្រីលោក ប្រាយុទ្ធ ចាន់អូចា និងគណៈរដ្ឋមន្ត្រី នឹងបរិច្ចាគប្រាក់ខែ យ៉ាងហោចណាស់មួយខែ ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុស Covid-19 ។

យោងតាមសារព័ត៌មាន Bangkok Post ចេញផ្សាយនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០ បានឱ្យដឹងថា លោកស្រី Narumon បាននិយាយថា ការប្រជុំគណៈរដ្ឋមន្ត្រី កាលពីថ្ងៃអង្គារ បានអនុម័តការបើកមូលនិធិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការផ្ទុះឡើង ដោយការចូលរួមវិភាគទានដំបូង បានមកពីនាយករដ្ឋមន្ត្រី និងសមាជិកគណៈរដ្ឋមន្ត្រី។

លោកស្រីបន្ថែមថា មូលនិធិនេះ នឹងជួយប្រជាជនបង់ថ្លៃដែលចាំបាច់ ដើម្បីការពារខ្លួន និងអ្នកដទៃទៀត ប្រឆាំងនឹងការរីករាលដាលនៃ Covid-19 ។

រដ្ឋមន្ត្រីការិយាល័យនាយករដ្ឋមន្ត្រី លោក Tewan Liptapallop បាននិយាយថា ក្នុងពេលជំណាលគ្នានោះ សម្តេចសង្ឃកំពូលបានបរិច្ចាគថវិកា ២ លានបាត ដើម្បីទិញម៉ាសមុខសម្រាប់ព្រះសង្ឃ នៅតាមវត្តនានាទូទាំងប្រទេសផងដែរ។ ប្រែសម្រួល: ណៃ តុលា

## ១៩. ដើមអម្ពិលៈ២ខែ ដើមឆ្នាំ២០២០ ទេសចរណ៍នៅវៀតណាម ធ្លាក់ចុះជាង ៦០%, វៀតណាមខាតបង់ ៤០លានដុល្លារ ដោយសារការរាលដាលជំងឺ Covid-19






បរទេស៖ ការផ្ទុះឡើងនៃជំងឺ Covid-19 បានធ្វើអោយការក្រុង ហូជីមិញ ខាតបង់យ៉ាងតិច ៩២០.៥ កោដិដុង (៤០ លានដុល្លារអាមេរិក) ក្នុងប្រាក់ចំណូលពីវិស័យទេសចរណ៍ ដែលភ្ញៀវទេសចរលុបចោល ផែនការធ្វើដំណើររបស់ពួកគេ។

យោងតាមសារព័ត៌មាន VN Express ចេញផ្សាយកាលពីចុងខែកុម្ភៈ ឆ្នាំ២០២០ បានឱ្យដឹងថា យោងតាមការស្ទង់មតិរបស់ក្រុមហ៊ុនទេសចរណ៍ធំ ៗ ចំនួន ២២ នៅក្នុងទីក្រុងនេះដោយ មន្ទីរទេសចរណ៍ក្រុង ហូជីមិញ បានឱ្យដឹងថា អ្នកទេសចរវៀតណាមនិងអន្តរជាតិជិត ៨៨.០០០ នាក់បានបោះបង់ចោលផែនការ មកទស្សនាទីក្រុងនេះ ចាប់តាំងពីមានការផ្ទុះឡើងនៃវីរុសរលាកផ្លូវដង្ហើមធ្ងន់ធ្ងរនេះ។

លោក Bui Ta Hoang Vu ប្រធាននាយកដ្ឋានទេសចរណ៍ បានប្រាប់អ្នកយកព័ត៌មានថា ការមកដល់នៃភ្ញៀវទេសចរបរទេសក្នុងរយៈពេល ២ ខែដំបូងបានធ្លាក់ចុះ ៦២ ភាគរយ កាលពីឆ្នាំមុន មកនៅជិត ៣៣៥.៨០០ នាក់។

សណ្ឋាគារ ភោជនីយដ្ឋាន និងមជ្ឈមណ្ឌលសន្និបាត កំពុងរាយការណ៍អំពីប្រាក់ចំណូលធ្លាក់ចុះ។ អ្នកខ្លះត្រូវអោយបុគ្គលិករបស់ខ្លួនលាឈប់ផងដែរ។

កម្លាំងបុគ្គលិកនៅមជ្ឈមណ្ឌល Novotel Saigon ក្នុងសង្កាត់លេខ៣ បានធ្លាក់ចុះ ២៥ ភាគរយហើយនៅសណ្ឋាគារ Tan Son Nhat Saigon មាន ២០ ភាគរយ។

ក្រុមហ៊ុនទេសចរណ៍ជាច្រើន បានលុបចោលការធ្វើដំណើរ ទៅកាន់ប្រទេសកូរ៉េខាងត្បូង ជប៉ុន និងអ៊ីតាលី ចន្លោះខែមីនានិងសីហា ដោយសារការផ្ទុះឡើងនៃវីរុសឆ្លង Covid-19។

យោងតាមក្រុមប្រឹក្សាប្រឹក្សា ទេសចរណ៍វៀតណាមបានឱ្យដឹងថា ការរីករាលដាលនៃជំងឺនេះអាចធ្វើឱ្យ ប្រទេសវៀតណាមខាតបង់ប្រាក់ចំណូល ដែលទទួលបានពីវិស័យទេសចរណ៍ពី ៧ ទៅ ១៥ ...ាន់លានដុល្លារក្នុងឆ្នាំនេះ ។

om

## ២០. ដើមអម្ពិល៖ ជំងឺ COVID-១៩៖ ប្រធានាធិបតីចិន គាំទ្រកិច្ចសហប្រតិបត្តិការ របស់អន្តរជាតិ ក្នុងការស្រាវជ្រាវ វិទ្យាសាស្ត្រ, សន្តិសុខសាធារណៈ ជាបញ្ហាប្រឈមទូទៅ ដែលប្រទេសទាំងអស់ គួរតែរួមគ្នាដោះស្រាយ



# គួរតែរួមគ្នាដោះស្រាយ

By CR101

Posted on March 4, 2020



ប៉េកាំង៖ នៅពេលដែលប្រទេសចិន កំពុងធ្វើសង្គ្រាម យ៉ាងស្វិតស្វាញ ប្រឆាំងនឹងការផ្ទុះឡើង នៃមេរោគថ្មីនៃជំងឺរលាកសួតធ្ងន់ធ្ងរ (COVID-១៩) ប្រធានាធិបតីចិនលោកស៊ី ជីនពីង បានគូសបញ្ជាក់ពី កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការស្រាវជ្រាវវិទ្យាសាស្រ្ត ដែលដឹកនាំដោយ ចក្ខុវិស័យ នៃសហគមន៍មួយ ដែលមានអនាគតរួមគ្នាសម្រាប់ មនុស្សជាតិ។

យោងតាម ទីភ្នាក់ងារព័ត៌មានចិន ស៊ិនហួ ចេញផ្សាយនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ បានឱ្យដឹងថា លោកស៊ីបានមានប្រសាសន៍ នៅក្នុងពេលចុះអធិការកិច្ចមួយ នៅទីក្រុងប៉េកាំង កាលពីថ្ងៃច័ន្ទថា សន្តិសុខសាធារណៈ គឺជាបញ្ហាប្រឈម ទូទៅមួយ ដែលមនុស្សជាតិ បានជួបប្រទះ ហើយប្រទេសទាំងអស់ គួរតែរួមគ្នាដោះស្រាយបញ្ហា នេះ។

ចាប់តាំងពីការផ្ទុះឡើង នៃជំងឺរាតត្បាត ប្រទេសចិនបានសហការ និងផ្លាស់ប្តូរព័ត៌មាន យ៉ាងសកម្មជាមួយ អង្គការសុខភាព ពិភពលោក (WHO) និងប្រទេសដទៃទៀត។

យោងតាមបេសកកម្មរួម របស់អង្គការសុខភាព ពិភពលោក-ចិន ស្តីពីជំងឺ COVID-19 បានបង្ហាញថា ហ្សែនដែលមានដំណើរតគ្នា នៃវីរុសថ្មី ត្រូវបានចែករំលែក ជាមួយអង្គការ សុខភាពពិភពលោក និងសហគមន៍អន្តរជាតិភ្លាមៗ បន្ទាប់ពីរោគសាស្រ្ត ត្រូវបានគេកំណត់ អត្តសញ្ញាណកាលពីថ្ងៃទី ៧ ខែមករា។

លោកស៊ី ប្រធានាធិបតីចិន ពេលជួបជាមួយលោក Tedros Adhanom Ghebreyesus អគ្គនាយកអង្គការសុខភាពពិភពលោក នៅទីក្រុងប៉េកាំងកាលពីថ្ងៃទី ២៨ ខែមករា បាននិយាយថា“ ការរីករាលដាលនេះគឺជាបិសាចមួយ, យើងនឹងមិនអនុញ្ញាតឱ្យវាលាក់ខ្លួនឡើយ” ៕

ប្រែសម្រួល: ណៃ តុលា

## ២១. ដើមអម្ពិលៈអ៊ីរ៉ង់ដោះលែង អ្នកទោស ៥៤.០០០នាក់ ជាបណ្ដោះអាសន្ន ដើម្បីប្រយុទ្ធនឹង រីករាលដាលជំងឺ Covid-19




BBC៖ ប្រទេសអ៊ីរ៉ង់ បានដោះលែង អ្នកទោសជាង ៥៤.០០០នាក់ ជាបណ្ដោះអាសន្ន ក្នុងកិច្ចប្រឹងប្រែងមួយ ដើម្បីប្រយុទ្ធប្រឆាំង នឹងការរីករាលដាល នៃជំងឺឆ្លងវីរុសថ្មី Covid-19 នៅក្នុងពន្ធនាគារ ដែលមានមនុស្សច្រើន ។

យោងតាមសារព័ត៌មាន BBC ចេញផ្សាយនៅព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០ បានឱ្យដឹងថា អ្នកនាំពាក្យតុលាការ លោក Gholamhossein Esmaili បានប្រាប់ ក្រុមអ្នកយកព័ត៌មានថា អ្នកទោសត្រូវបានអនុញ្ញាត ឱ្យចេញពីពន្ធនាគារ បន្ទាប់ពីការធ្វើតេស្ត អវិជ្ជមានសម្រាប់ Covid-19 និងការនៅក្រៅឃុំ។ “ អ្នកទោសដែល បង្កអសន្តិសុខខ្លាំង” ដែលត្រូវបានផ្ដន្ទាទោស ដាក់ពន្ធនាគារ លើសពី ៥ ឆ្នាំនឹងមិនត្រូវបាន ដោះលែងឡើយ។

បុគ្គលិកធ្វើ ការសប្បុរសធម៌ ជនជាតិអង់គ្លេស ដើមកំណើតអ៊ីរ៉ង់ ដែលជាប់ពន្ធនាគារ គឺលោកស្រី Nazanin Zaghari-Ratcliffe អាចនឹងត្រូវបានដោះលែងឆាប់ៗ។ នេះបើយោងតាម សមាជិក សភាអង់គ្លេស។

លោកស្រី Tulip Siddiq បានដកស្រង់សំដី ឯកអគ្គរដ្ឋទូតអ៊ីរ៉ង់ ប្រចាំនៅចក្រភពអង់គ្លេស ថា លោកស្រី Zaghari-Ratcliffe “អាចនឹងត្រូវដោះលែង នៅថ្ងៃនេះឬថ្ងៃស្អែក” ៕

ប្រែសម្រួល: ណៃ តុលា

# ២២. ដើមអម្ពិល៖WHO៖ ប្រទេសជប៉ុន និងកូរ៉េខាងត្បូង ស្ថិតនៅក្នុងទីតាំង កង្វល់ដ៏ធំបំផុត សម្រាប់វីរុសកូរ៉ូណា




ហ្សឺណែវ៖ ប្រធានអង្គការសុខភាពពិភពលោក កាលពីថ្ងៃច័ន្ទបានចាត់ទុក ការរីករាលដាលនៅក្នុងប្រទេសអ៊ីរ៉ង់ អ៊ីតាលី ជប៉ុន និងកូរ៉េខាងត្បូងថាជា “ការព្រួយបារម្ភដ៏ធំបំផុត” ដោយលើកឡើងពីការកើនឡើងនូវករណីឆ្លងវីរុសថ្មីនៅក្នុងប្រទេសទាំង៤។

អគ្គនាយករងអង្គការ សុខភាពពិភពលោកលោក Tedros Ghebreyesus បានប្រាប់សន្និសីទសារព័ត៌មានមួយថា “យើងស្ថិតនៅក្នុងទឹកដី ដែលមិនអាចគ្រប់គ្រងបាន” ខណៈពេលដែលសង្កត់ធ្ងន់ថា ការផ្ទុកវីរុសនេះ គឺអាចធ្វើទៅបានហើយ ត្រូវតែជាអាទិភាពកំពូល សម្រាប់ប្រទេសទាំងអស់។

យោងតាមទិន្នន័យរបស់ អង្គការសុខភាពពិភពលោកមនុស្សជិត ៨៨.០០០នាក់នៅក្នុង ៦២ ប្រទេសបានឆ្លងវីរុសនេះ ដែលមានឈ្មោះថា COVID-១៩ ដែលបណ្ដាលឲ្យមនុស្សជាង ២,៨០០ នាក់ស្លាប់នៅជុំវិញពិភពលោក ៕

ដោយ ឈូក បូរ៉ា

## ២៣. ដើមអម្ពិលៈអង់គ្លេស អាចនឹងឱ្យប្រជាជន ធ្វើការពីផ្ទះមកយ៉ាងហោចណាស់ ៣ខែ ដើម្បីបញ្ឈប់ការរីករាលដាលវីរុស Covid-19




បរទេស៖ អ្នកធ្វើការនៅអង់គ្លេស អាចត្រូវបានគេប្រាប់អោយ ស្នាក់នៅក្នុងផ្ទះរហូតដល់ទៅ ៣ ខែ នៅពេលប្រទេសនេះ ត្រៀមសំរាប់ការផ្ទុះឡើងនៃ ជំងឺឆ្លងដ៏ធំមួយក្នុងរយៈពេល ប៉ុន្មានសប្តាហ៍នេះ។

យោងតាមសារព័ត៌មាន Business Insider ចេញផ្សាយកាលពីយប់ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ បានឱ្យដឹងថា នាយករដ្ឋមន្ត្រីអង់គ្លេសលោក Boris Johnson នៅថ្ងៃអង្គារនេះបានដាក់ចេញផែនការសកម្មភាព របស់រដ្ឋាភិបាលរបស់លោក សម្រាប់ការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃវីរុសឆ្លង Covid-19 នៅទូទាំងប្រទេស។ មានករណីឆ្លងចំនួន ៥១ ករណីដែលបានបញ្ជាក់នៅក្នុងចក្រភពអង់គ្លេស គិតត្រឹមម៉ោងថ្ងៃត្រង់ថ្ងៃអង្គារ។

រដ្ឋាភិបាលលោក Boris Johnson បច្ចុប្បន្នផ្តោតសំខាន់លើការ ទប់ស្កាត់ជំងឺនេះដែលបានសាយភាយស្ទើរតែគ្រប់ប្រទេស នៅអឺរ៉ុបខាងលិច និងបានឆក់យកជីវិតមនុស្សជាង ៣.០០០ នាក់នៅទូទាំងពិភពលោក៕

om ប្រសម្រួល: ណៃ តុលា